**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពត**

សំណុំរឿងរដ្ឋប្បវេណីលេខ ២៩២
ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២
**សាលក្រមលេខ: ៤៩ "ខ"**
ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣

# សាលក្រមរដ្ឋប្បវេណី
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពត

-កាលបរិច្ឆេទបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ។
-កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣ ។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពត

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

**ដើមចោទ៖**

- ឈ្មោះ [redacted] ភីរម្យ ភេទស្រី កើតឆ្នាំ១៩៦១ ជនជាតិខ្មែរ មានអាសយដ្ឋានស្ថិត[redacted] ។

អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted] អត្តលេខ២៥៩១T ដែលមានការិយាល័យ[redacted]។

**សហចុងចម្លើយ៖**

១. ឈ្មោះ [redacted]សាវ៉ន ភេទប្រុស កើតថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៥៦ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted]។

២. ឈ្មោះ [redacted] សោភ័ន ភេទស្រី មានទីលំនៅបច្ចុប្បន្ននៅ[redacted]។

## អង្គហេតុ និងចំណុចវិវាទ:

### ១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖

បញ្ជាក់អត្ថិភាពនៃសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុដីស្រែទំហំ៦៩៨៥ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងធំ ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត មានព្រំប្រទល់ខាងជើងទល់ឈ្មោះ [redacted] សាវ៉ន ខាងត្បូងទល់ឈ្មោះ [redacted] ភីរម្យ, [redacted] ឈីវ ខាងលិចទល់ឈ្មោះ [redacted] ម៉ៅ, [redacted] ហុង និងខាងកើតទល់ឈ្មោះ [redacted] សាវ៉ន ដល់ដើមចោទឈ្មោះ [redacted] ភីរម្យ។

### ២. ការពន្យល់ត្រួសៗអំពីរឿងក្តី ៖

តាមពាក្យបណ្តឹងចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ដើមចោទឈ្មោះ [redacted] ភីរម្យ មានខ្លឹមសារថា កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩២ ដើមចោទឈ្មោះ [redacted] ភីរម្យ បានទិញដីមួយកន្លែងពីឈ្មោះ [redacted] សុភ័ណ្ឌ ដោយបានធ្វើលិខិតបញ្ជាក់ និងទទួលស្គាល់ពីគណកម្មការភូមិចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩២ ចុះហត្ថលេខា ដោយលោក [redacted] គេង។ បន្ទាប់មកនៅឆ្នាំ២000

ដើមចោទឈ្មោះ [redacted] ភីរម្យ បានដូរដីមួយកន្លែងទៀតជាមួយឈ្មោះ [redacted] សាវ៉ន ដើម្បីឱ្យដីស្រែដែលបានទិញនោះ ជាប់ជាមួយដីកេរម្តាយរបស់ខ្លួន ព្រោះដីរបស់ឈ្មោះ [redacted] សាវ៉ន នៅចំកណ្តាលរវាងដីខ្លួន និងដីកេរម្តាយខ្លួន ការដូរនេះពុំបានធ្វើលិខិតបញ្ជាក់អ្វីឡើយ។ បន្ទាប់ពីទិញដីពីឈ្មោះ [redacted] សុភ័ណ្ឌ និងដូរដីពីឈ្មោះ [redacted] សាវ៉ន រួចហើយ ដើមចោទឈ្មោះ [redacted] ភីរម្យ បានកាន់កាប់ដីនោះរហូតមកដល់បច្ចុប្បន្ន។ ក្នុងអំឡុងពេលកាន់កាប់ដើមចោទបានបំពេញលក្ខខណ្ឌនៃការកាន់កាប់អចលនវត្ថុដោយសន្តិវិធី ដឹងលឺជាសាធារណៈ ដោយមានឆន្ទៈយកធ្វើជាកម្មសិទ្ធិ ដោយសុចរិត គ្មានកំហុស និងមានរយៈពេល២២ឆ្នាំមកហើយ។ ខាងសុរិយោដីបានចុះមកវាស់វែងរួចហើយ ប៉ុន្តែពុំចេញប្លង់កម្មសិទ្ធិអោយដើមចោទឈ្មោះ [redacted] ភីរម្យ នោះទេ ទើបដើមចោទមកដាក់ពាក្យបណ្តឹងបញ្ជាក់អត្ថិភាពនៃសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុដីស្រែខាងលើតែម្តង។

**៣.ចំណុចវិវាទមានៈ រឿងក្តីនេះពុំមានចំណុចវិវាទទេ។**

**៤. ការអះអាងរបស់គាគី និងសាក្សីៈ**

-ដើមចោទឈ្មោះ [redacted] **ភីរម្យ** បានឆ្លើយថា៖ ឈ្មោះ [redacted] ចរិយា តែម្នាក់ទេ ដែលបានអះអាងថា ដីនេះមានប្រភពមកពីដីទំនាស់ ហើយដីខាងលើ ពុំមានទំនាស់ទេ ជាដីដែលខ្លួនបានដូរ និងទិញតាំងពីឆ្នាំ២០០០មក ដីទាំងនេះនៅជាប់គ្នា។ ប្អូនខ្លួនឈ្មោះ [redacted] ចរិយា រស់នៅខេត្តកំពត។ ចំពោះឈ្មោះ [redacted] ចរិយា នៅតែទាមទារដីកេរម្តាយ។ ឈ្មោះ [redacted] **ចរិយា** បានដីកេរដែរ គឺនៅក្នុងប្លង់ ២១៩ ដែលអ្នកឈរឈ្មោះ ដាក់ឈ្មោះ [redacted] ចាន់ណារី ប្លង់លេខ២២២ មិនទាន់ដាក់ឈ្មោះនរណាទេ លេខ២២៣ អោយទៅបងប្រុស [redacted] ដារុធ និងលេខ២២៤ ជាដីចំណែករបស់ខ្ញុំទទួលអំណោយពីម្តាយ។ ចំពោះឈ្មោះ [redacted] ចរិយា ថាដីកេរនេះ ជាដីកេរ ដែរ ខ្ញុំមិនដឹងមូលហេតុអីទេ គាត់បំពាន និយាយស្តាប់គ្នាមិនបាន។ ពេលដែលសុរិយោដីចុះវាស់វែង ឈ្មោះ [redacted] ចរិយា ប្តឹងទៅខាងសុរិយោដី ហើយពេលដោះស្រាយ [redacted] ចរិយា អត់បានចូលរួមទេ កាលនោះ ហើយមូលហេតុអីក៏ខ្ញុំមិនដឹងទេ។ តាំងពីពេលនោះមកមិនមានខាងសុរិយោដីកោះហៅទៀតទេ ហើយក៏មិនមានអ្នកប្តឹងទៀតដែរ។ ខ្លួនកាន់កាប់ដាក់ស្តែងកន្លងមករហូតដល់បច្ចុប្បន្ន ចំពោះបងប្អូនផ្សេងទៀត ក៏មិនមានអ្នកណាប្តឹងដែរ។ ខ្លួនបានតវ៉ាចំពោះអ្នកវាស់ដែរ តែគាត់មិនដឹងថាសម្រេចមិចចេះតែវាស់ទៅ។ ដីនេះខាងសុរិយោដី បានវាស់បែងចែកជា៥ប្លង់។ ខ្លួនចាំខាងសុរិយោដីយូរពេក ទើបដាក់ពាក្យបណ្តឹងមកតុលាការតែម្តង។ ចំពោះលិខិតបញ្ជាក់ នោះ ពេលនោះខ្លួនគិតថាគ្រប់គ្រាន់ហើយ ពេលទិញមានលិខិតនេះ ហើយដល់ពេលដូរជាមួយលោក [redacted] សាវ៉ន អត់មានធ្វើលិខិតទេ ព្រោះគិតថាដីជាប់គ្នា។ ខ្លួនទិញដីតាំងពីឆ្នាំ១៩៩២ ដីស្រែខ្លួន។

- សហាចុងចម្លើយឈ្មោះ [redacted] **សាវ៉ន** បានឆ្លើយថា៖ ដីរបស់ខ្លួននៅកណ្តាលដីដើមចោទ។ ដីរបស់ដើមចោទទិញពីគេដែរ តែមិនដឹងទិញដីពីឈ្មោះណាទេ ដីខ្លួននៅទីនោះ តែខ្លួនមិនបានរស់នៅទីនោះទេ ដីនោះជាដីស្រែ នៅភូមិត្រពាំងធំ ទិញតាំងពីឆ្នាំ២០០០ ហើយខ្លួនដូរតាំងពីអំឡុងឆ្នាំ២០០០។ ចំពោះដីដែលក្រុមការងារចុះវាស់វែង នៅព្រំខាងជើង និងខាងកើត និងបានប្លង់រឹងអស់ហើយ ហើយបានផ្ទេរទៅកូនស្រីឈ្មោះ [redacted] សុគន្ធថាវឌី។ ព្រំដីមានចំណុចយាមការ ភ្លឺស្រែ ហើយឥលូវ ដាំឈូក ហើយ ដីរបស់ដើមចោទ ដាំឈូកដែរ ហើយដើមចោទអ្នកអាស្រ័យផល។ ចំពោះដីកេរម្តាយ និងដីដូរ គឺដាច់ដោយឡែកពីគ្នា។ ដីកេរម្តាយមានរបងត្រឹមត្រូវ ហើយដីដែលដើមចោទដូរ ពុំមានរបងទេ។ ឈ្មោះ [redacted] ចរិយា ដែលមានទំនាស់ ជាដីទំនាស់កេរម្តាយគាត់ទេ តែមិនដឹងយ៉ាងមិចសុរិយោដី មិនចេញប្លង់ដីឱ្យគាត់ចំពោះដីទិញ។ ចំពោះដីដើមចោទ ទិញពីឈ្មោះ [redacted] សោភ័ន ទិញជាមាស។ កូនស្រីខ្លួនឈ្មោះ [redacted] សុគន្ធថាវឌី បានទៅរៀននៅឯប្រទេសចិនហើយ ហើយប្លង់ខ្លួនបានកាត់ឈ្មោះឱ្យឈ្មោះ [redacted] សុគន្ធថាវឌី រួចហើយ តែខ្លួននៅអាស្រ័យផល។

-សាក្សីឈ្មោះ [redacted] **សុភីន** ជាមេឃុំត្រពាំងធំ បានឆ្លើយថា៖ ខ្លួនធ្វើការ៥អាណត្តិហើយ តែទើបតែធ្វើជាមេឃុំបីអាណត្តិនេះទេ។ ក្នុងកំណត់ហេតុរបាយការណ៍របស់សុរិយោដី ខ្លួនបានអានរួចហើយ។ ដើមចោទ [redacted] ភីរម្យ, ឈ្មោះ [redacted] ណារុធ និង [redacted] ចរិយា ប្តឹងរឿងទំនាស់កេរគាត់។ ដើមបណ្តឹង ពេលនោះមិនបានចូលទេ។ ការកំណត់ដីទំនាស់ គឺអាជ្ញាធរមិនហ៊ាន កំណត់ខ្លួនឯងទេ។ កំណត់ហេតុនេះខាងសុរិយោដីអ្នកធ្វើ ខាងអាជ្ញាធរគ្រាន់តែចូលរួមទេ។ កាលនោះ លោកស្រី [redacted] ភីរម្យ បានចូលរួម តែដើមបណ្តឹងមិនបានចូលរួមទេ។ តាំងពីកំណត់ហេតុ២០១៥ នេះមក ខាងដើមបណ្តឹងមិនឃើញមក



Scanned with CamScanner

ដាក់ពាក្យបណ្ដឹងទៀតទេ។ ខ្លួនស្គាល់ទីតាំងដីនោះ ហើយទំនាស់គឺតែដីកេរម្ដាយគាត់ ចំពោះដីស្រែខ្លួន មិនដឹងទេ។ ខ្លួនមិនដែលបានចូលភូមិនោះផ្ទាល់សោះ។ អ្នកកំណត់គឺខាងសុរិយោដី ជាអ្នកកំណត់។ ចំពោះដីស្រែ ខ្លួនមិនដឹងទេ ខ្លួនដឹងតែដីកេរខាងម្ដាយគាត់ទេ។ ឈ្មោះ [redacted] ចរិយា នៅមូលដ្ឋានឃុំត្រពាំងភ្លាំង ប៉ុន្តែឈ្មោះ [redacted] ណារុធ មិនដឹងគាត់រស់នៅឯណាទេ ពុំមានរស់នៅមូលដ្ឋាននេះទេ។ ចំពោះលិខិតអញ្ជើញ ខាងសុរិយោដី គេជាអ្នកកោះហៅភាគីទំនាស់ ហើយខាងអាជ្ញាធរគ្រាន់តែចូលរួមស្ដាប់ទេ។ ចំពោះប្លង់ ឬលិខិតទិញលក់ពុំឃើញមានការបង្ហាញអ្វីនៅពេលខាងសុរិយោដីកោះហៅដោះស្រាយវិវាទនោះ។ ចំពោះដីដែលឈ្មោះ [redacted] សាវ៉ន បានទិញ ខ្លួនមិនបានដឹងទេ ហើយរឿងដូរដីគ្នារវាង [redacted] សាវ៉ន និង [redacted] ភីរម្យ ខ្លួនក៏មិនបានដឹងដែរ គាត់ដូរដីតែគ្នាគាត់ ខ្លួនមិនបានដឹងទេ។ រាល់ដងពេលមានទំនាស់រឿងដី ខាងសុរិយោដីគេអ្នកវាស់វែង ហើយចេញទិន្នន័យដីសម្គាល់ដីទំនាស់ឬអត់។ កាលនោះឈ្មោះ [redacted] ចរិយា បានប្ដឹងទៅខាងសុរិយោដី។ នីតិវិធីខាងសុរិយោដីរាល់ឯកសារចុះវាស់វែង បើភាគីមិនព្រមផ្ដិតមេដៃ ខាងសុរិយោដី ដាក់ថាមានទំនាស់។ ខ្លួនស្គាល់ឈ្មោះ [redacted] តេង ជាគណៈកម្មការភូមិ ចំពោះលិខិតបញ្ជាក់របស់លោក [redacted] តេង ខ្លួនមិនដឹងអក្សរ ឬហត្ថលេខាគាត់ទេ តែឈ្មោះ [redacted] តេង ពិតជាគណៈកម្មការភូមិមែន។

-សាក្សីឈ្មោះ [redacted] **អែម** ជាមេភូមិត្រពាំងធំ បានឆ្លើយថា៖ ខ្លួនឈ្មោះ [redacted] អែម ខ្លួនជាមេភូមិត្រពាំងធំ ឃុំត្រពាំង ខ្លួនធ្វើតាំងពីឆ្នាំ២០០៦ មក ខ្លួនរស់នៅតាំងពីឆ្នាំ១៩៧៩ មកម្លេះ រស់នៅឆ្ងាយពីដើមចោទ ១០០ម៉ែត្រ។ ចំពោះដីដើមចោទកាលនោះធ្វើប្លង់ជាប្រព័ន្ធ ចំពោះឈ្មោះ [redacted] ចរិយា ពុំមានបង្កាន់ដៃ ដូច្នេះខាងសុរិយោដីប្រាប់ថា បើមិនមានបង្កាន់ដៃ ពុំមានប្លង់ទេ។ ចំពោះដីកេរម្ដាយ និងដីដើមចោទទិញគឺផ្សេងពីគ្នា ដោយដីកេរមានរបងឃាំងស្រាប់ ដីគាត់ទិញជាដីស្រែ ដែលនៅជាប់គ្នា។ ដីដើមចោទទិញ នេះ ពុំមានពាក់ព័ន្ធដីទំនាស់រឿងដីកេរម្ដាយទេ។ ម្ដាយឈ្មោះ [redacted] ភីរម្យ ឈ្មោះ [redacted] ឈឺវ មានកូនចំនួន០៦នាក់ ចំពោះចំណែក ខ្លួនពុំចាំថា ចែងប៉ុន្មានចំណែកទេ។ ខ្លួនធ្វើស្រែនៅម្ដុំនិងដែរ ខ្លួនអត់បានចូលរួមទេ ពេលវាស់វែងនោះ អនុប្រធានភូមិចូលរួម។ ដីនោះមានរបង ឈើ លួសបន្លា។ ម្ដាយ [redacted] ភីរម្យ ស្លាប់អត់ចាំឆ្នាំទេ គាត់ស្លាប់នៅពេលវាស់វែងតែម្ដង ឈ្មោះ [redacted] ភីរម្យ អ្នកបែងចែក។ ដំបូងដើមចោទ គាត់ទិញពីឈ្មោះ [redacted] សោភ័ន និងបានដូរពី [redacted] សាវ៉ន ចំពោះឯកសារទៅឃុំពុំមានទេ ហើយឈ្មោះ [redacted] សាវ៉ន គាត់ទិញដីពីគេដែរ គាត់ធ្វើស្រែ ក្រោយមកគាត់ក៏ដូរដីជាមួយ អ៊ុត ភីរម្យតែម្ដង។ ដីនេះ ឈ្មោះ [redacted] ភីរម្យ គាត់កាន់កាប់រហូតមក គាត់ទិញលក់ ដូរតែគ្នាគាត់ពុំឆ្លងកាត់អាជ្ញាធរដឹងលឺទេ។ ឈ្មោះ [redacted] ចរិយា ពេលចែកចំណែកដីកេរម្ដាយ ពុំមានចំណែកគាត់ទេ។ ដីមានរបង លួសបន្លា ខ្លួនដឹងថា ដើមចោទទិញដីពីឈ្មោះ [redacted] សោភ័ន នៅផ្ទះជាប់ខ្លួនតែម្ដង ទិញដីគិតជាមាស ដីស្រែ នៅជាប់ដីឈ្មោះ [redacted] សាវ៉ន ហើយក៏បានដូរគ្នា។

-សាក្សីឈ្មោះ [redacted] **យ៉ានី** ជាប្អូនថ្លៃរបស់ដើមចោទបានឆ្លើយថា៖ ខ្លួនរស់នៅកំពង់ត្រាច ខ្លួនត្រូវជាប្អូនថ្លៃរបស់ឈ្មោះ [redacted] ភីរម្យ ហើយប្រពន្ធរបស់ឈ្មោះ [redacted] សំណាង ខ្លួនពីមុនរស់នៅជាមួយម្ដាយក្មេកឈ្មោះ [redacted] ឈឺវ មានកូន៦នាក់ ស្រី២ ប្រុស៤។ ខ្លួនរស់នៅជាមួយម្ដាយក្មេក បាននៅផ្ទះនោះ បានប្រហែល៣ឆ្នាំ ខ្លួនអត់ចាំទំហំ ហើយដីមានរបង របងឈើ ដាក់បន្លាលួស។ ដីបងឈ្មោះ [redacted] ភីរម្យ មានដីស្រែខាងក្រោយ មានព្រំប្រទល់ដីខាងក្រោយ ខាងជើងរបង ដីកេរម្ដាយមានរបងស្រាប់ ចំពោះដីស្រែបងភីរម្យ ជាដីស្រែ។ ដីរបស់បងថ្លៃដឹង ដោយសារម្ដាយក្មេកថា ដីស្រែជាដីរបស់បងថ្លៃ គាត់បានធ្វើស្រែពេលខ្លះខ្លួនទៅជួយដែរ។ ឈ្មោះ [redacted] ចរិយា បានបែកផ្ទះ ហើយរស់នៅផ្ទះផ្សេងហើយ។ ចំពោះដីកេរម្ដាយខ្លួនមិនដឹងទំហំទេ ហើយពេលគេចុះវាស់ ដីកេរម្ដាយមានចំណែកដីប្ដីខ្លួន តែមិនដឹងលេខប្លង់លេខប៉ុន្មានទេ។ ពេលនោះឈ្មោះ [redacted] ភីរម្យ រស់នៅក្បែរនោះដែរ មានផ្ទះ២ មានផ្ទះម្ដាយក្មេង និងផ្ទះឈ្មោះ [redacted] ភីរម្យ។ ចំពោះម្ដាយក្មេកខ្លួន អត់ដែលលឺនិយាយពីការបែងចែកអោយឈ្មោះ [redacted] ចរិយា ទេ។

-សាក្សីឈ្មោះ [redacted] **ហាន** ជាប្អូនបង្កើតរបស់ដើមចោទបានឆ្លើយថា៖ ខ្លួនរស់នៅភូមិត្រពាំងធំ ជាមួយម្ដាយ ខ្លួនជាប្អូនបង្កើតរបស់ដើមចោទឈ្មោះ [redacted] ភីរម្យ ម្ដាយខ្លួនឈ្មោះ [redacted] ឈឺវ កូនម្ដាយខ្លួន មាន៦នាក់។ ដីកេរម្ដាយមិនដឹងទំហំប៉ុន្មានទេ។ ព្រំខាងជើង ទល់ដីស្រែរបស់បងស្រីខ្លួន ខាងត្បូងទល់ផ្លូវថ្នល់ ខាងជើង និងខាងកើតទល់ដីរបស់ឈ្មោះ [redacted] សាវ៉ន។ ខ្លួនបែកពី



Scanned with CamScanner

ម្ដាយនៅឆ្នាំ១៩៩៤ ឬ១៩៩៥ ពេលនោះ ដីម្ដាយខ្លួនមានរបង ហើយខ្លួនជាអ្នកជួយធ្វើរបង ធ្វើគ្នា២,៣នាក់ ហើយធ្វើតាំងពីឆ្នាំ ១៩៩៤, ១៩៩៥។ បងប្អូនខ្លួនឈ្មោះ [redacted] ណារុធ [redacted] ភីរម្យ, ខ្លួនឈ្មោះ [redacted] ហាន , [redacted] ចំណាន និង [redacted] ចរិយា រស់នៅផ្សេង ជិតគ្នាដែរ ហើយម្ដាយស្លាប់ឆ្នាំ២០១៣។ បងខ្លួន [redacted] ណារុធ អ្នកបែងចែកអោយខ្លួន ហើយឥលូវមិនទាន់ធ្វើប្លង់ចេញទេ ដោយសារ [redacted] ចរិយា ទាមទារចង់បានដី។ ដីស្រែដើមចោទ មិនពាក់ព័ន្ធដីកេរម្ដាយទេ។ ចំពោះ [redacted] ចរិយា ទាមទារខ្លួនមិនដឹងថាមិចទេ គាត់ចេះតែទារ។ ដីស្រែ បានទិញ កាលពីឆ្នាំ១៩៩៤,១៩៩៥ ដីប្រភពដើមមិនដឹងរបស់ពីណាទេ ដីធ្វើស្រែមិនបាន ហើយអ្នកភូមិក៏លក់ឱ្យបងស្រីខ្លួន ហើយបងស្រីខ្លួនក៏ទិញយក។ ខ្លួនធ្វើទាហាន តាំងពីឆ្នាំ១៩៩០ ជាងមក។ ខ្លួនយូរៗទៅលេងផ្ទះម្ដាយម្ដង បង្គោលឈើ នៅដដែល។ ខ្លួនរស់នៅជាមួយម្ដាយ តាំងពីកើតមក។ កាលនោះធ្វើរបង ព័ទ្ធតែដីម្ដាយទេ ព្រោះកុំឱ្យគោ ចូលស៊ី ដីស្រែបង ភីរម្យ មិនមានរបងទេ។ ខ្លួនពុំស្គាល់ឈ្មោះ [redacted] សោភ័ន ទេ ដឹងតែគាត់រស់នៅភូមិនោះ។

- លោកមេធាវី [redacted] ជាអ្នកតំណាងអាណត្តិឱ្យដើមចោទឈ្មោះ [redacted] **ភីរម្យ** បានធ្វើការទាញហេតុផលចុងក្រោយថា៖ កូនក្ដីខ្លួនសូមរក្សាសេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ របស់ខ្លួន ដែលបានដាក់ជូនតុលាការ។ ឆ្លងតាមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ និង ត្រៀមសម្រាប់ការទាញហេតុផលលើកទី២ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ មានលក្ខណៈស្របគ្នា។ ហើយចុងចម្លើយ ក៏បានទទួលស្គាល់អង្គហេតុ ហើយកិរិយានៃការកាន់កាប់ កូនក្ដីខ្លួនបានកាន់កាប់ដោយសុចរិត ជារហូតមក ជាប់លាប់ ដឹងលឺជាសាធារណៈ មិនមានហិង្សាទេ បានធ្វើលទ្ធកម្ម កម្មសិទ្ធិស្របច្បាប់ ហើយការកាន់កាប់របស់កូនក្ដីខ្លួន មានរយៈពេលជាង២០ឆ្នាំឯណោះ។ ចំពោះការតវ៉ា ពុំមានអ្នកណាមកតវ៉ាទេ ដូច្នេះផ្អែកលើអាជ្ញាយុកាល នៃការកាន់កាប់ កូនក្ដីខ្លួនសូមស្នើសុំឱ្យតុលាការសម្រេចបញ្ជាក់ពីអត្ថិភាពកម្មសិទ្ធិ នៃសិទ្ធិកម្មសិទ្ធិ ដល់ឈ្មោះ អ៊ុត ភីរម្យ តាមច្បាប់។

- ដើមចោទឈ្មោះ [redacted] **ភីរម្យ** បានធ្វើការទាញហេតុផលចុងក្រោយ ដូចការលើកឡើងរបស់មេធាវីតំណាងដោយអាណត្តិរបស់ខ្លួន។

- សហចុងចម្លើយឈ្មោះ [redacted] **សាវ៉ន** បានធ្វើការទាញហេតុផលចុងក្រោយថា៖ ខ្លួនសំណូមពរឱ្យតុលាការសម្រេចឱ្យដើមចោទធ្វើប្លង់កម្មសិទ្ធិបានផង។

**៥. ការពិនិត្យភស្តុតាង៖**

-លិខិតបញ្ជាក់ការទិញលក់ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩២ របស់គណៈកម្មការភូមិឈ្មោះ កែវ តេង។ (ថតចម្លង)

-របាយការណ៍លេខ០១៣៧ ដនសស/កព ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត។ (ច្បាប់ដើម)

-កំណត់ហេតុស្ដីពីការសាកសួរពត៌មានជុំវិញទំនាស់ក្បាលដី ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥។ (ថតចម្លង)

-សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ របស់មេធាវី ពេញ សុភក្ដិ ។ (ច្បាប់ដើម)

-តារាងនិយាមការចំណុចគោលព្រំដី (ថតចម្លង) ។

## សំអាងហេតុ

**ឆ្លងតាមលទ្ធផលសាកសួរដើមចោទ ចុងចម្លើយ សាក្សី និងពិនិត្យភស្តុតាងនៅនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖**

១. តាមពាក្យបណ្ដឹងរបស់ដើមចោទ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ,ពាក្យកែតម្រូវ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ និង ពាក្យកែតម្រូវចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ បានស្នើសុំមកតុលាការចេញសាលក្រម បញ្ជាក់អត្ថិភាពនៃសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុដីស្រែទំហំ៦៨៤៥ម$^2$ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងធំ ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត មានព្រំប្រទល់ខាងជើងទល់ឈ្មោះ [redacted] សាវ៉ន ខាងត្បូងទល់ឈ្មោះ [redacted] ភីរម្យ, [redacted] ឈឿវ ខាងលិចទល់ឈ្មោះ [redacted] ម៉ៅ, [redacted] ហុង និងខាងកើតទល់ឈ្មោះ [redacted] សាវ៉ន ដោយផ្អែកលើអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុដោយការកាន់កាប់



Scanned with CamScanner

ដល់ដើមចោទឈ្មោះ [redacted] ភិរម្យ។ ផ្អែកតាមរបាយការណ៍លេខ១៣៧ ដនសស/កព ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ របស់មន្ទីររៀបចំដែនដី នគររូបនីយកម្មសំណង់ និងសុរិយោដីខេត្តកំពត បានបញ្ជាក់ថា ដីដែលមានឈ្មោះ [redacted] **ភិរម្យ** មានទីតាំងភូមិត្រពាំងធំ ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត មានក្បាលដីលេខ០២២៥ មានទំហំ៦៩៨៤ម$^{២}$ ដែលមានព្រំប្រទល់ ខាងជើងទល់នឹងឈ្មោះ [redacted] សុគន្ធថាវឌី, ខាងត្បូងទល់នឹង [redacted] សំអុល ដីទំនាស់ ខាងកើតទល់នឹង [redacted] សុគន្ធថាវឌី និងខាងលិចទល់នឹង [redacted] គន្ធី ,[redacted] សំអុល។ ឃើញថា ដើមចោទ និងចុងចម្លើយបានអះអាង និងទទួលស្គាល់ទំហំ និងព្រំប្រទល់ដែលមន្ទីររៀបចំដែនដី នគររូបនីយកម្មសំណង់ និងសុរិយោដីខេត្តកំពត បានបញ្ជាក់មកតុលាការ ថាពិតជាមានទំហំ៦៩៨៤ម$^{២}$ ដែលមានព្រំប្រទល់ ខាងជើងទល់នឹងឈ្មោះ [redacted] សុគន្ធថាវឌី, ខាងត្បូងទល់នឹង [redacted] សំអុល, ដីទំនាស់ (ដីកេរម្ដាយឈ្មោះ ឈុន ឈឺវ) ខាងកើតទល់នឹង [redacted] សុគន្ធថាវឌី និងខាងលិចទល់នឹង [redacted] គន្ធី, [redacted] សំអុល ប្រាកដមែន ដោយសារព្រំប្រទល់ក្នុងពាក្យបណ្ដឹងខាងជើងទល់ឈ្មោះ [redacted] សារ៉ន និងខាងកើតទល់ឈ្មោះ [redacted] សារ៉ន ដោយឈ្មោះ [redacted] សារ៉ន បានផ្ទេរកម្មសិទ្ធិទៅឱ្យកូនស្រីឈ្មោះ [redacted] សុគន្ធថាវឌី រួចហើយ។ ដូច្នេះដីដែលដើមចោទស្នើសុំមកតុលាការមានទីតាំងស្ថិតនៅភូមិត្រពាំងធំ ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត មានទំហំ**៦៩៨៤ម$^{២}$** មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] សុគន្ធថាវឌី ខាងត្បូងទល់នឹង [redacted] សំអុល, ដីទំនាស់ (ដីកេរម្ដាយឈ្មោះ ឈុន ឈឺវ) ខាងកើតទល់នឹង [redacted] សុគន្ធថាវឌី និងខាងលិចទល់នឹង [redacted] គន្ធី, [redacted] សំអុល មានភាពច្បាស់លាស់ គប្បីតុលាការលើកយកមកពិនិត្យ និងសម្រេចបាន។

២. តាមការអះអាងរបស់ដើមចោទឈ្មោះ [redacted] **ភិរម្យ** និងចុងចម្លើយឈ្មោះ [redacted] **សារ៉ន** បានបញ្ជាក់ថា ដើមចោទបានទិញដីស្រែមួយកន្លែងពីឈ្មោះ [redacted] **សោភ័ន** នៅឆ្នាំ១៩៩២ នៅភូមិត្រពាំងធំ ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត ហើយចុងចម្លើយឈ្មោះ [redacted] **សារ៉ន** មានដីស្រែមួយកន្លែង ដែលមានទីតាំងជាប់គ្នា ហើយដីចុងចម្លើយ នៅចំចន្លោះកណ្ដាលដីរបស់ដើមចោទ។ នៅឆ្នាំ២០០០ ដើមចោទបានដូរដីជាមួយសហចុងចម្លើយឈ្មោះ [redacted] សារ៉ន ដើម្បីឱ្យដីរបស់ដើមចោទទាំងពីរកន្លែងនៅជាប់គ្នា។ ក្រោយពីដើមចោទ បានដូរដីជាមួយចុងចម្លើយឈ្មោះ [redacted] សារ៉ន រួចមក ដើមចោទ បានកាន់កាប់ ដីនោះ ធ្វើស្រែ និងដាំឈូក រហូតមកដល់បច្ចុប្បន្ន ប្រាកដមែន។ ដោយឡែកសហចុងចម្លើយឈ្មោះ [redacted] **សោភ័ន** ដែលបានលក់ដីស្រែមកឱ្យដើមចោទឈ្មោះ [redacted] **ភិរម្យ** បានអនុវត្តសិទ្ធិ និងកាតព្វកិច្ចចប់សព្វគ្រប់មកឱ្យដើមចោទរួចហើយ ។

តាមរបាយការណ៍លេខ១៣៧ ដនសស/កព ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ របស់មន្ទីររៀបចំដែនដី នគររូបនីយកម្មសំណង់ និងសុរិយោដីខេត្តកំពត បានបញ្ជាក់ថាទីតាំងដីស្ថិតនៅភូមិត្រពាំងធំ ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត ត្រូវបានចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងបានចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរួចហើយ ចំពោះក្បាលដីណាដែលបានបំពេញនីតិវិធីគ្រប់គ្រាន់។ ចំណែកអចលនវត្ថុដែលស្នើសុំបញ្ជាក់របស់ឈ្មោះ [redacted] ភិរម្យ នេះជាក្បាលដីទំនាស់ មានក្បាលដីលេខ ០៧០៧១៩០៣-០២២៥ មានទំហំ**៦៩៨៤ម$^{២}$** ដែលមានព្រំប្រទល់ ខាងជើងទល់នឹងឈ្មោះ [redacted] សុគន្ធថាវឌី, ខាងត្បូងទល់នឹង [redacted] សំអុល ដីទំនាស់ (ដីកេរម្ដាយឈ្មោះ [redacted] ឈឺវ) ខាងកើតទល់នឹង [redacted] សុគន្ធថាវឌី និងខាងលិចទល់នឹង [redacted] គន្ធី, [redacted] សំអុល។ ផ្អែកតាមកំណត់ហេតុសាកសួរពត៌មានជុំវិញក្បាលដីទំនាស់ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ដើមបណ្ដឹងឈ្មោះ [redacted] ណារុធ និងឈ្មោះ [redacted] ចរិយា អវត្តមាន ពុំបានចូលមកអះអាងអំពីការទាមទារ និងមូលហេតុទាមទារលើក្បាលដីណាមួយឡើយ ចំណែកឈ្មោះ [redacted] ភិរម្យ ឆ្លើយអះអាងអំពីដីស្រែ តាំងពីឆ្នាំ១៩៩២ ដែលខ្លួនបានទិញ ជាដីដោយឡែកពី ដីកេរម្ដាយរបស់ខ្លួន។ ឃើញថា ចាប់តាំងពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ មក ពុំមានអ្នកពាក់ព័ន្ធណា ធ្វើការតវ៉ាបញ្ជាក់អំពីក្បាលដីទំនាស់ខាងលើនេះឡើយ។ ហេតុដូច្នេះ ផ្អែកតាមការអះអាងរបស់ដើមចោទ ចុងចម្លើយ សាក្សី និងភស្តុតាងជាឯកសារនានា អាចអោយតុលាការជឿបានថា ដីស្រែរបស់ដើមចោទឈ្មោះ [redacted] ភិរម្យ មានក្បាលដីលេខ០៧០៧១៩០៣-**០២២៥** មានទំហំ**៦៩៨៤ម$^{២}$** ស្ថិតនៅភូមិត្រពាំងធំ ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត ដែលមានព្រំប្រទល់ ខាងជើងទល់នឹងឈ្មោះ [redacted] សុគន្ធថាវឌី, ខាងត្បូងទល់នឹង [redacted] សំអុល ដីទំនាស់ (ដីកេរម្ដាយឈ្មោះ [redacted] ឈឺវ) ខាងកើតទល់នឹង [redacted] សុគន្ធថាវឌី និងខាងលិចទល់នឹង [redacted] គន្ធី, [redacted] សំអុល ជាដីស្រែដែលដើមចោទបានទិញ ពីឈ្មោះ [redacted] **សោភ័ន** និងបានដូរដី

ជាមួយឈ្មោះ [redacted] **សាវ៉ន** ចាប់តាំងពីអំឡុងឆ្នាំ២០០០ មក ហើយបានកាន់កាប់រហូតមកដល់បច្ចុប្បន្ន។ ដីស្រែខាងលើនេះ មិនស្ថិតក្នុងដីទំនាស់ ដែលជាដីកេររបស់ម្តាយដើមចោទនោះឡើយ។

ដូច្នេះតុលាការកំណត់បានថា ដើមចោទបានកាន់កាប់ដីខាងលើដោយសន្តិវិធី ដោយសុចរិត និងគ្មានកំហុស តាមរយៈការទិញលក់ និងដូរជាមួយសហចុងចម្លើយ ប្រាកដមែន។

៣. តាមការបំភ្លឺរបស់សាក្សីជាអាជ្ញាធរឈ្មោះ [redacted] **សុភ័ន** ជាមេឃុំត្រពាំងធំ ឈ្មោះ [redacted] **អែម** ជាមេភូមិត្រពាំងធំ សាក្សីឈ្មោះ [redacted] **យ៉ានី** ជាប្អូនថ្លៃរបស់ដើមចោទ និងសាក្សីឈ្មោះ [redacted] **ហាន** ជាប្អូនបង្កើតរបស់ដើមចោទ បានបញ្ជាក់ថា ដីស្រែមួយកន្លែង ដែលស្ថិតនៅភូមិត្រពាំងធំ ឃុំត្រពាំងធំ របស់ដើមចោទឈ្មោះ [redacted] **ភិរម្យ** ធ្លាប់បានទិញពីប្រជាជននៅទីនោះ (ឈ្មោះ [redacted] សោភ័ន) និងបានដូរដីជាមួយសហចុងចម្លើយឈ្មោះ [redacted] សាវ៉ន ក្រោយមកដើមចោទបានកាន់កាប់ជាក់ស្តែងលើដីស្រែនោះតាំងពីឆ្នាំ២០០០ មករហូតដល់បច្ចុប្បន្ន ដោយដើមចោទបានធ្វើស្រែចំការ និងដាំឈូកជារៀងរាល់ឆ្នាំ ប្រាកដមែន។

ដូច្នេះការអះអាងរបស់ភាគីដើមចោទ ចុងចម្លើយ និងសាក្សី មានភាពស៊ីសង្វាក់គ្នានឹងភស្តុតាងលិខិតបញ្ជាក់ការទិញលក់ដី ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩២ រវាងអ្នកលក់ឈ្មោះ [redacted] សោភ័ន និងអ្នកទិញឈ្មោះ [redacted] ភិរម្យ ដែលមានគណៈកម្មការភូមិឈ្មោះ [redacted] តេង បានដឹងលឺ ដោយបានបញ្ជាក់ពីកម្មសិទ្ធិរបស់ដើមចោទ ពុំមានវិវាទ បូករួមនឹងការទទួលស្គាល់អង្គហេតុរបស់ចុងចម្លើយឈ្មោះ [redacted] សាវ៉ន ដែលបានដូរដីជាមួយដើមចោទ និងការទទួលស្គាល់អង្គហេតុស្នើសុំបញ្ជាក់កម្មសិទ្ធិរបស់ដើមចោទ។ តុលាការទទួលស្គាល់ថា ដើមចោទពិតបានទិញដីស្រែមួយកន្លែងនៅឆ្នាំ១៩៩២ និងបានដូរដីជាមួយសហចុងចម្លើយឈ្មោះ [redacted] **សាវ៉ន** នៅអំឡុងឆ្នាំ២០០០ ដីដែលមានទីតាំងស្ថិតនៅភូមិត្រពាំងធំ ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត និងបានកាន់កាប់ អាស្រ័យផល ដោយធ្វើស្រែ និងដាំឈូក ដោយមានការដឹងលឺជាសាធារណៈនិងមានឆន្ទៈយកជាកម្មសិទ្ធិ ប្រាកដមែន។

៤. យោងតាមមាត្រា១៦២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា “ *២-ជនដែលបានកាន់កាប់អចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ១០ (ដប់) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនោះ បើជននោះសុចរិត និង គ្មានកំហុស នៅពេលដែលខ្លួនបានចាប់ផ្តើមកាន់កាប់។*”

តាមអង្គហេតុ និងអង្គច្បាប់ខាងលើ តុលាការកំណត់បានថា ដើមចោទពិតជាបានកាន់កាប់ ធ្វើស្រែ ដាំឈូកលើអចលនវត្ថុ (ដី) មានក្បាលដីលេខ០៧០៧១៩០៣-០២២៥ មានទំហំ៦៩៨៤ម$^2$ ស្ថិតនៅភូមិត្រពាំងធំ ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត មានព្រំប្រទល់ ខាងជើងទល់នឹងឈ្មោះ [redacted] សុគន្ធថាវឌី, ខាងត្បូងទល់នឹង [redacted] សំអុល ដីទំនាស់ (ដីកេរម្តាយឈ្មោះ [redacted] ឈើវ) ខាងកើតទល់នឹង [redacted] សុគន្ធថាវឌី និងខាងលិចទល់នឹង [redacted] គន្ធី, [redacted] សំអុល ចាប់តាំងពីអំឡុងឆ្នាំ២០០០ ដោយមានរយៈពេលជាង២០ឆ្នាំមកហើយ។ ដើមចោទបានកាន់កាប់ដោយសន្តិវិធី ដឹងលឺជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ដោយសុចរិត និងគ្មានកំហុស នៅពេលដែលដើមចោទបានចាប់ផ្តើមកាន់កាប់ ហេតុដូច្នេះការស្នើសុំរបស់ដើមចោទ ឱ្យតុលាការទទួលស្គាល់ អត្ថិភាពនៃសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុដីស្រែទំហំ៦៩៨៤ម$^2$ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងធំ ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត មានព្រំប្រទល់ ខាងជើងទល់នឹងឈ្មោះ [redacted] សុគន្ធថាវឌី, ខាងត្បូងទល់នឹង [redacted] សំអុល ដីទំនាស់(ដីកេរម្តាយឈ្មោះ [redacted] ឈើវ) ខាងកើតទល់នឹង [redacted] សុគន្ធថាវឌី និងខាងលិចទល់នឹង [redacted] គន្ធី, [redacted] សំអុល គប្បីតុលាការសម្រេចតាមការស្នើសុំរបស់ដើមចោទ ស្របតាមបញ្ញត្តិមាត្រា១៦២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា។

៥. ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

**១** -បញ្ជាក់ថា ដើមចោទឈ្មោះ [redacted] **ភិរម្យ** មានអត្ថិភាពនៃសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុដីស្រែ ដែលមានក្បាលដីលេខ **០៧០៧១៩០៣-០២២៥** ទំហំ៦៩៨៤ម$^2$ (ប្រាំមួយពាន់ប្រាំបួនរយប៉ែតសិបបួនម៉ែត្រការ៉េ) មានទីតាំងស្ថិតនៅភូមិត្រពាំងធំ



Scanned with CamScanner

ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] សុគន្ធថាវឌី, ខាងត្បូងទល់នឹង [redacted] សំរុល ដីចំនាស់ (ដីកេរម្តាយឈ្មោះ [redacted] ឈឺវ) ខាងកើតទល់នឹង [redacted] សុគន្ធថាវឌី និងខាងលិចទល់នឹង [redacted] គន្ធី, [redacted] សំរុល ។

២ - ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

-សាលក្រមនេះ គូភាគីអាចប្តឹងឧទ្ធរណ៍តាមមាត្រា២៦០ និងមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា**

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ពស.២៥៦៦

កំពត, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]